ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិស្តីពីស្វាយចន្ទី
# ឆ្នាំ២០២២-២០២៧

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣

**រៀបចំ និងបោះពុម្ពដោយ:**

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

**ឧបត្ថម្ភគាំទ្រការបោះពុម្ពដោយ:**

សហព័ន្ធស្វាយចន្ទីកម្ពុជា (សចក)
កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍ
សេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)
ការពង្រឹងប្រព័ន្ធកសិកម្មបន្សាំអាកាសធាតុ (CRAS) របស់
ជីអាយហ្សិតកម្ពុជា
ហេក្សកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិស្តីពីស្វាយចន្ទី
# ឆ្នាំ២០២២-២០២៧

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

ក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ដើម្បីពង្រឹងនិងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅក្នុងទិសដៅសម្រេចឱ្យបានពេញលេញនូវគោលដៅប្រកបដោយចីរភាព និងចក្ខុវិស័យរបស់កម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានផ្តោតការយកចិត្តទុកដាក់លើការបង្កើនផលិតភាពនិងការប្រកួតប្រជែង តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅក្នុងសកម្មភាពដែលមានតម្លៃខ្ពស់ ដោយបានចាត់ទុកវិស័យកសិកម្មជាវិស័យនាំមុខមួយក្នុងចំណោមវិស័យផ្សេងទៀត ដែលបានរួមចំណែកក្នុងការជំរុញកំណើនផលទុនជាតិនិងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ ក្នុងឆ្នាំ២០២០-២០២១ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានដល់សុខភាពសាធារណៈ សង្គម សេដ្ឋកិច្ច នៅគ្រប់បណ្តាប្រទេសទាំងអស់លើសកលលោក ដែលក្នុងនោះ សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ ក៏រអិលធ្លាក់ចុះក្នុងអត្រា-៣,១ភាគរយ ដោយសារ ការធ្លាក់ចុះនៃវិស័យសេវាកម្មនិងវិស័យឧស្សាហកម្ម ខណៈវិស័យកសិកម្មនៅតែរក្សាបានកំណើនវិជ្ជមាន ដែលនេះបានបង្ហាញឱ្យឃើញថា វិស័យកសិកម្មនៅតែជាវិស័យសក្តានុពលនិងមានភាពធន់។ វិស័យកសិកម្មបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់សន្តិសុខស្បៀង ផ្តល់ការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋដែលពឹងអាស្រ័យលើវិស័យនេះ។

បច្ចុប្បន្ននេះ ផលិតផលកសិកម្មកម្ពុជាភាគច្រើនដែលមិនទាន់បានកែច្នៃ ត្រូវបាននាំចេញទៅកាន់ប្រទេសជិតខាង ដែលធ្វើឱ្យកម្ពុជាទទួលបានតម្លៃបន្ថែមទាប ក្នុងនោះផលិតផលស្វាយចន្ទីកម្ពុជា ត្រូវបានប្រទេសជិតខាងធ្វើការកែច្នៃនិងនាំចេញបន្តទៅប្រទេសដទៃទៀត។ ក្នុងន័យនេះ ដើម្បីបន្តជំរុញដល់កំណើនកសិពាណិជ្ជកម្ម ប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព និងសុវត្ថិភាព ជាពិសេសដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សារឱ្យមានលក្ខណៈពាណិជ្ជកម្ម ការរៀបចំនិងការដាក់ចេញនូវគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ពិតជាមានសារៈសំខាន់ ដែលស្របជាមួយនឹងការដាក់ចេញនូវគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្រផ្សេងៗទៀត សំដៅធានាបាននូវឧត្តមភាពនៅលើទីផ្សារក្នុងស្រុក ក្នុងតំបន់ និងពិភពលោក។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងការដឹកនាំរៀបចំគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ និងសូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ

លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជនទាំងអស់ ចំពោះការចូលរួមយ៉ាងសកម្មនិងប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការសហការនិងគាំទ្រដល់ការរៀបចំគោលនយោបាយនេះឡើង។

ជាមួយនឹងការសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការនូវគោលនយោបាយជាតិស្ដីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងវិស័យសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍ សហគមន៍អ្នកដាំដុះ អ្នកកែច្នៃ និងអ្នកនាំចេញ សូមរួមគ្នាគាំទ្រនិងចូលរួមអនុវត្តគោលនយោបាយនេះឱ្យទទួលបានលទ្ធផលជាក់ស្ដែងនិងមានប្រសិទ្ធភាពខ្ពស់តាមការរំពឹងទុក សំដៅរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍវិស័យដំណាំកសិឧស្សាហកម្មស្វាយចន្ទីកម្ពុជា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាពនិងបរិយាបន្ន។

ថ្ងៃ សុក្រ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០២៣

**ហ៊ុន សែន**

# មាតិកា

**អារម្ភកថា**

**១. សេចក្តីផ្តើម** ........ **១**

១.១. ស្ថានភាពនៃការរីកលូតលាស់របស់ផលិតកម្មស្វាយចន្ទី ........ ២

១.២. ការកែច្នៃនិងទីផ្សារ ........ ៣

**២. ចក្ខុវិស័យ** ........ **៥**

**៣. គោលបំណងនិងគោលដៅ** ........ **៥**

**៤. យុទ្ធសាស្ត្រ** ........ **៥**

៤.១. យុទ្ធសាស្ត្រនៃការផលិត ........ ៦

៤.២. យុទ្ធសាស្ត្រនៃការកែច្នៃ ........ ៦

៤.៣. យុទ្ធសាស្ត្រនៃការនាំចេញ ........ ៧

**៥. ផែនការសកម្មភាព** ........ **៨**

៥.១. ការបង្កើតយន្តការ ........ ៨

៥.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត ........ ៩

៥.៣. ការគាំទ្រហិរញ្ញវត្ថុ ........ ៩

៥.៤. ការអភិវឌ្ឍធនធានមនុស្ស ........ ៩

៥.៥. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ........ ៩

៥.៦. ដំណើរការអនុវត្តគម្រោង ........ ១០

៥.៦.១. ផលិតកម្មដំណាំស្វាយចន្ទី ........ ១០

៥.៦.២. ការកែច្នៃផលិតផលស្វាយចន្ទី ........ ១២

៥.៦.៣. ទីផ្សារនិងការនាំចេញស្វាយចន្ទី ........ ១៤

**៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ** ........ **១៦**

**៧. សេចក្តីសន្និដ្ឋាន** ........ **១៦**

**សន្ទានុក្រម**

**ឧបសម្ព័ន្ធទី១ : ម៉ាទ្រីកនៃមិធានការគោលនយោបាយជាតិស្តីពីស្វាយចន្ទី និង ផែនការសកម្មភាព**

**ឧបសម្ព័ន្ធទី២ : តារាងជិន្នន័យ**

## ១. សេចក្ដីផ្ដើម

សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២០ បានធ្លាក់ចុះ-៣,១ភាគរយ និងកើនដល់៥,៩ភាគរយក្នុងឆ្នាំ២០២១ ស្របពេលដែលប្រទេសមានសេដ្ឋកិច្ចខ្ពស់ទាំង៥ក្នុងអាស៊ាន(ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន វៀតណាម និងថៃ) មានការធ្លាក់ចុះ-៣,៤ភាគរយនៅឆ្នាំ២០២០ និងកើនដល់២,៩ភាគរយក្នុងឆ្នាំ២០២១ ដែលជាកំណើនទាបជាងការរំពឹងទុក ដោយសារការរីករាលដាលខ្លាំងនៃជំងឺកូវីដ-១៩[1]។ ប្រទេសកម្ពុជាជាប្រទេសមានសេដ្ឋកិច្ចបើកចំហ ដូចនេះកម្ពុជាមិនអាចគេចរួចពីផលអវិជ្ជមានមកលើសង្គម សេដ្ឋកិច្ចនោះទេ។ ជាក់ស្តែងនៅឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះក្នុងអត្រា-៣,១ភាគរយ និងត្រូវបានវាយតម្លៃកើនឡើង៣,០ភាគរយនៅឆ្នាំ២០២១ និងត្រូវបានព្យាករកើនឡើងក្នុងរង្វង់៥,៦ភាគរយនៅឆ្នាំ២០២២ គឺដោយសារតែការឆ្លើយតបទាន់ពេលវេលារបស់រាជរដ្ឋាភិបាលកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មីនៃការរស់នៅជាមួយកូវីដ-១៩ និងការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចប្រទេសដែលជាដៃគូពាណិជ្ជកម្មកម្ពុជា[2] តាមរយៈការជំរុញការនាំចេញផលិតផលមួយចំនួន ដូចជាកង់ គ្រឿងបង្គុំអេឡិចត្រូនិក អង្ករ និងផលិតផលកសិកម្មផ្សេងៗទៀតដែលបានបន្តរក្សាកំណើនល្អ ស្របពេលដែលរាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តវិធានការអន្តរាគមន៍ ក្នុងការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងទិសដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ យុទ្ធសាស្ត្រចម្បងរបស់រាជរដ្ឋាភិបាល គឺយកចិត្តទុកដាក់លើការបង្កើនផលិតភាព ការប្រកួតប្រជែង និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅក្នុងវិស័យ ដែលមានតម្លៃបន្ថែមខ្ពស់ ដោយចាត់ទុកវិស័យកសិកម្មនិងវិស័យកែច្នៃម្ហូបអាហារ គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀត ដែលបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ បង្កើតការងារ កាត់បន្ថយចំណាកស្រុកនិងភាពក្រីក្រ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តផ្តោតលើការអនុវត្តការងារជាអាទិភាពសំខាន់ៗ ក្នុងមុំនៃការលើកស្ទួយវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ ដោយលើកកម្ពស់ឧស្សាហកម្មកែច្នៃ តាមរយៈការជំរុញឱ្យមានការវិនិយោគឯកជនលើកសិផលមានសក្តានុពល ក្នុងនោះដំណាំស្វាយចន្ទីក៏ជាដំណាំអាទិភាពមួយក្នុងចំណោមដំណាំអាទិភាពទាំង១២មុខ[3] ផងដែរ។ ស្វាយចន្ទីកម្ពុជាមានកេរ្តិ៍ឈ្មោះល្បី ជាពិសេសការទទួលស្គាល់ពីទីផ្សារលើទំហំគ្រាប់ស្វាយចន្ទី រសជាតិ កម្រិតកាកសំណល់កសិកម្មទាប និងសរីរាង្គតាមបែបប្រពៃណី។

---

[1] ប្រភពទិន្នន័យពីរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២១

[2] ប្រភពទិន្នន័យពីរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

[3] ប្រភពទិន្នន័យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣



## ១.១. ស្ថានភាពនៃការរីកលូតលាស់របស់ផលិតកម្មស្វាយចន្ទី

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដាំដុះស្វាយចន្ទីកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់។ នៅចន្លោះឆ្នាំ២០១៥ដល់ឆ្នាំ២០១៩ ផ្ទៃដីដាំដុះបានកើនឡើងពី៩៤ ៣០៨ហិកតាដល់២២៨ ០៣៧ហិកតា និងផ្ទៃដីប្រមូលផលកើនពី៧៨ ៥៨៤ហិកតាដល់១៤៥ ៨៤០ហិកតា។ ទិន្នផលសរុបដែលទទួលបានមានកំណើនពី៩៣ ៩៤៤តោនដល់២០៨ ៧៦៩តោន។ មកទល់នឹងឆ្នាំ២០២១ កំណើនផ្ទៃដីដាំដុះស្វាយចន្ទីមាន៤០៥ ៩៩១ហិកតា និងផ្ទៃដីប្រមូលផលមាន២៧៥ ៦៧៩ហិកតា ដែលទិន្នផល ជាមធ្យមទទួលបាន ១.៧៤តោន ក្នុងមួយហិកតា និងទទួលបានបរិមាណផលសរុបប្រមាណ៤៧២ ៦៣៦តោនក្នុង១ឆ្នាំ[4]។ ទោះបីជាមានការកើនឡើងបែបនេះក្តី ដំណាំស្វាយចន្ទីនៅមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ និងយកចិត្តទុកដាក់ បច្ចេកទេសដាំដុះ ពូជល្អ ផ្តល់ទិន្នផលខ្ពស់ គ្មានជំងឺ និងធន់ទៅនឹងការរាតត្បាតពីសមាសភាពចង្រៃនិងការប្រែប្រួលអាកាសធាតុ ការប្រមូលផល ការកែច្នៃ និងការស្តុកទុក ដែលពុំទាន់អនុវត្តតាមស្តង់ដាបច្ចេកទេសត្រឹមត្រូវ សមត្ថភាពកែច្នៃនៅមានកម្រិតទាំងបច្ចេកទេសនិងបរិមាណ និងធនធានមនុស្ស។

គិតត្រឹមឆ្នាំ២០១៨ ប្រជាជននៅជនបទដែលកំពុងប្រកបរបរដាំដុះដំណាំស្វាយចន្ទី មានប្រមាណ ៧ម៉ឺនគ្រួសារ ក្នុងនោះការដាំបែបគ្រួសារដែលមានផ្ទៃដីក្រោម៥ហិកតា មាន៧៨ភាគរយ និងធំជាង១០ហិកតា មាន៦ភាគរយ។ ខេត្តចំនួន១០ដែលមានផ្ទៃដីដាំដំណាំស្វាយចន្ទីច្រើនជាងគេ មានខេត្តកំពង់ធំ រតនគិរី ក្រចេះ កំពង់ចាម ព្រះវិហារ ស្ទឹងត្រែង ឧត្តរមានជ័យ ត្បូងឃ្មុំ មណ្ឌលគិរី និងខេត្តសៀមរាប។ ពូជស្វាយចន្ទីដែលកសិករនិយមដាំនៅកម្ពុជា មានពូជM23 M10 M1 IM4 និងពូជH09។ ទីតាំងកែច្នៃផលិតផលពាក់កណ្តាលសម្រេច មាននៅខេត្តត្បូងឃ្មុំ កំពង់ធំ កំពង់ស្ពឺ និងខេត្តកណ្តាល។[5] មកទល់នឹងឆ្នាំ២០២០ សិប្បកម្មកែច្នៃ ផលិតផលស្វាយចន្ទីមានចំនួន១២[6] ក្រុមហ៊ុនវិនិយោគកែច្នៃគ្រាប់ស្វាយចន្ទីមានចំនួន៤[7] និងក្រុមហ៊ុននាំចេញមានចំនួន៥៩[8]។ នៅឆ្នាំ២០១៩ កម្ពុជាជាប្រទេសជាប់លំដាប់ទី១០ ដែលមានការដាំដុះដំណាំស្វាយចន្ទីក្នុងចំណោមប្រទេសដាំដុះធំៗនៅលើពិភពលោក។ ប្រទេសកូតឌីវ័រ គឺជាប្រទេសដែលមានផ្ទៃដី ប្រមូលផលស្វាយចន្ទីច្រើនជាងគេលើពិភលោក ដែលមានផ្ទៃដីដាំដុះស្វាយចន្ទីប្រមាណ ១ ៩១៣ ០៧៣ ហិកតា និងទទួលបានទិន្នផលសរុប៧៩២ ៦៧៨តោនក្នុង១ឆ្នាំ។ ប្រទេសចំនួន៩ទៀត មានផ្ទៃដីប្រមូល ផលច្រើនបន្ទាប់ រួមមានឥណ្ឌា តង់សានី បេណាំង ឥណ្ឌូណេស៊ី ប្រេស៊ីល ហ្គីណេប៊ីស្សូ ប៊ុរុនឌី វៀតណាម និងកម្ពុជា[9]។

[4] ប្រភពទិន្នន័យ: របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០២១ និងទិសដៅការងារសម្រាប់ឆ្នាំ២០២២

[5] ប្រភពទិន្នន័យ: របាយការណ៍វាយតម្លៃខ្សែច្រវាក់តម្លៃស្វាយចន្ទីកម្ពុជា (ខែធ្នូ ឆ្នាំ២០១៩)-HEKs EPER

[6] ប្រភពទិន្នន័យ: ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[7] ប្រភពទិន្នន័យ: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

[8] ប្រភពទិន្នន័យ: នាយកដ្ឋាននាំចេញនាំចូលនៃក្រសួងពាណិជ្ជកម្ម

[9] ប្រភពទិន្នន័យ: អង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ(FAO)

### ១.២_ ការកែច្នៃនិងទីផ្សារ

ផលិតកម្មកែច្នៃគ្រាប់ស្វាយចន្ទី ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកវិនិយោគក្នុងស្រុកនិងបរទេស ប៉ុន្តែសមត្ថភាពក្នុងការគ្រប់គ្រងគុណភាព អនាម័យ និងកែច្នៃកសិផលរបស់កម្ពុជា នៅមានកម្រិតនៅឡើយ។ ដើម្បីជំរុញផលិតកម្ម កម្ពុជាត្រូវការចាំបាច់នូវបច្ចេកទេសកែច្នៃនិងរោងចក្រកែច្នៃខ្នាតធំដែលមានគុណភាពនិងអនាម័យត្រឹមត្រូវ។ កម្ពុជាអាចផលិតគ្រាប់ស្វាយចន្ទីបានប្រមាណជាង២០ម៉ឺនតោនក្នុង១ឆ្នាំ តែបច្ចុប្បន្នកម្ពុជាបានកែច្នៃគ្រាប់ស្វាយចន្ទីបានប្រមាណត្រឹមតែ៥ភាគរយប៉ុណ្ណោះ ហើយគ្រាប់ស្វាយចន្ទីស្រស់មួយភាគធំត្រូវបាននាំចេញទៅកាន់ប្រទេសជិតខាង ដែលជាហេតុធ្វើឱ្យកម្ពុជាបាត់បង់តម្លៃបន្ថែម និងការងារយ៉ាងច្រើន រួមទាំងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះគ្រាប់ស្វាយចន្ទីកម្ពុជា ដែលមានរសជាតិឈ្ងុយឆ្ងាញ់ទៀតផង។ នាពេលអនាគត កម្ពុជានឹងពង្រីកទីផ្សារស្វាយចន្ទីបន្ថែមលើទីផ្សារប្រទេសជិតខាងដែលមានស្រាប់។ ទោះបីជាយ៉ាងនេះក្តី កម្ពុជាក៏នៅមានបញ្ហាប្រឈមពិតប្រាកដមួយ គឺខ្សែច្រវាក់នៃការផ្គត់ផ្គង់ស្វាយចន្ទីស្រស់មកដល់ដៃអ្នកកែច្នៃមិនទាន់មានភាពរឹងមាំ ដោយកសិករអ្នកដាំដុះនៅមានភាពជឿជាក់លើទីផ្សារប្រទេសជិតខាងដែលទទួលទិញគ្រាប់ស្វាយចន្ទីមិនទាន់កែច្នៃ។

នៅក្នុងឆ្នាំ២០២០ ផលប៉ះពាល់នៃជំងឺឆ្លងកូវីដ-១៩ជាសកល បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ក្នុងវិបត្តិយ៉ាងជ្រៅ និងបានបណ្តាលឱ្យខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់និងពិភពលោកមានភាពរអាក់រអួលនិងកាត់ផ្តាច់ក្នុងកម្រិតធ្ងន់ធ្ងរ។ ជាក់ស្តែង តម្រូវការទីផ្សារពិភពលោកចំពោះគ្រាប់ស្វាយចន្ទីមានសម្បកមានការធ្លាក់ចុះយ៉ាងគំហុកនៅឆ្នាំ២០២០ ដែលការបញ្ជាទិញមានការថយចុះប្រមាណ១ ៥០៧លានដុល្លារអាម៉េរិក បើធៀបនឹងឆ្នាំ២០១៩ ក្នុងនោះប្រទេសឥណ្ឌាបានធ្វើការនាំចូលស្វាយចន្ទីមានសម្បកច្រើនជាងគេ ដោយប្រទេសវៀតណាមឈរនៅលំដាប់ទី២ ក្នុងចំណោមប្រទេសនាំចូលធំៗទាំង១០។ ក៏ប៉ុន្តែក្នុងរយៈពេល៤ឆ្នាំ(ឆ្នាំ២០១៦-២០១៩) ប្រទេសវៀតណាមបាននាំមុខក្នុងការនាំចូលស្វាយចន្ទីមានសម្បកដែលមានចំណែកទីផ្សារនាំចូលប្រមាណជា៥៣,៤០ភាគរយ នៃចំណែកទីផ្សារពិភពលោកស្មើនឹងទឹកប្រាក់ចំនួន១ ៥៨៦លានដុល្លារអាម៉េរិក ហើយប្រទេសឥណ្ឌាឈរនៅលំដាប់ទី២ដែលមានចំណែកទីផ្សារ៤៣,៩៧ភាគរយនៃចំណែកទីផ្សារពិភពលោក ស្មើនឹងទឹកប្រាក់ចំនួន១ ៣០៦លានដុល្លារអាម៉េរិក។ ការនាំចូលគ្រាប់ស្វាយចន្ទីមានសម្បកលើទីផ្សារពិភពលោក មានការធ្លាក់ចុះពី២ ៨៥៦លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៩មកត្រឹម១ ៣៤៩លានដុល្លារអាម៉េរិក នៅឆ្នាំ២០២០[10]។ តម្រូវការគ្រាប់ស្វាយចន្ទីគ្មានសម្បក មានការថយចុះប្រមាណជា១៣ភាគរយ ដែលមានទឹកប្រាក់នាំចូលសរុប៣ ៨៣៥លានដុល្លារអាម៉េរិក នៅឆ្នាំ២០២០ធៀបទៅនឹងឆ្នាំ២០១៩ មានទឹកប្រាក់នាំចូលសរុបចំនួន៤ ៤១១លានដុល្លារអាម៉េរិក។ នៅឆ្នាំ២០២០សហរដ្ឋអាម៉េរិកមានតម្រូវការទីផ្សារស្វាយចន្ទីគ្មានសម្បកខ្ពស់ជាងគេ រហូតដល់ទៅ២៨,៧៦ ភាគរយនៃ

[10] ប្រភពទិន្នន័យពី: ផែនទីពាណិជ្ជកម្ម ITC, ទិន្នន័យដកស្រង់ក្នុងខែតុលា ឆ្នាំ២០២០

ចំណែកទីផ្សារពិភពលោក ដែលមានទឹកប្រាក់នាំចូលសរុបចំនួន១ ១០៣លានដុល្លារអាម៉េរិក។ ប្រទេសចំនួន៥ផ្សេងទៀតកំពុងមានតម្រូវការខ្ពស់លើផលិតផលស្វាយចន្ទីគ្មានសម្បកនេះ ដូចជាប្រទេសអាល្លឺម៉ង់មានចំណែកទីផ្សារ១២,៧៨ភាគរយ ប្រទេសហូឡង់មានចំណែកទីផ្សារ៨,៩៩ភាគរយ ប្រទេសចិន មានចំណែកទីផ្សារ៣,៩៤ភាគរយ ចក្រភពអង់គ្លេសមានចំណែកទីផ្សារ៣,៨៩ភាគរយ និងប្រទេសបារាំងមានចំណែកទីផ្សារ៣,១៣ភាគរយ។

ទោះបីជាវិបត្តិនេះនៅតែបន្តអូសបន្លាយយ៉ាងនេះក្ដី ក្នុងឆ្នាំ២០២០ ប្រទេសកម្ពុជាបាននាំចេញផលិតផលកសិកម្មសរុប៤,៨លានតោន ទៅកាន់ទីផ្សារអន្តរជាតិ ក្នុងនោះគ្រាប់ស្វាយចន្ទីមានប្រមាណ ២១៨ ៩៨១តោន[11] និងក្នុងឆ្នាំ២០២១ កម្ពុជាបាននាំចេញគ្រាប់ស្វាយចន្ទីមានចំនួន៩៣៧ ៩៧៤,២៦តោន (កើនឡើងចំនួន៣២៨,៣៤ភាគរយ) នាំចេញទៅប្រទេសវៀតណាមចំនួន៩២៨ ៩២៦,២៧តោន ប្រទេសចិនចំនួន៤ ៥៥២,៦៩តោន ប្រទេសថៃចំនួន៤ ២៩៧,៤០តោន ប្រទេសឥណ្ឌាចំនួន៩៨,៦០តោន ប្រទេសជប៉ុនចំនួន៥៤,១៥តោន ប្រទេសកូរ៉េចំនួន២១,៣៨តោន ប្រទេសអារ៉ាប់ចំនួន១៤,៥១តោន ប្រទេសហូឡង់ចំនួន៨,២១តោន ប្រទេសបង់ក្លាដែសចំនួន៧តោន ប្រទេសឡាវចំនួន៤តោន ប្រទេសស្វ៊ីសចំនួន០,០២តោន ប្រទេសតូហ្គោចំនួន០,០១តោន ប្រទេសអារ៉ាប់រួមចំនួន០,០១តោន ប្រទេសហ្វីលីពីន ចំនួន០,០០៣តោន និងប្រទេសបារាំងចំនួន០,០០២តោន[12]។ ស្របពេលដែលផលិតផលស្វាយចន្ទីរបស់ប្រទេសផលិតធំៗក្នុងពិភពលោកមិនមានកំណើន ផលិតផលស្វាយចន្ទីរបស់កម្ពុជាអាចទាញយកចំណែកទីផ្សារពីសហរដ្ឋអាម៉េរិក អាល្លឺម៉ង់ ហូឡង់ ចិន ចក្រភពអង់គ្លេស បារាំង អូស្ត្រាលី កាណាដា សហភាពអារ៉ាប់រួម និងប្រទេសជប៉ុន[13]។ និន្នាការនៃតម្រូវការគ្រាប់ស្វាយចន្ទីរបស់អឺរ៉ុបមានការកើនឡើងនាពេលបច្ចុប្បន្នលើការប្រើប្រាស់គ្រាប់ស្វាយចន្ទីជំនួសគ្រាប់ធញ្ញជាតិដទៃទៀត មានដូចជា អាល់ម៉ុន(Almonds), ហាហ្សែលណាត់(Hazelnuts) និងភីស្តាស៊ីស្យូ(Pistachios) ដែលមានការខ្វះខាតហើយតម្លៃថ្លៃជាង។ ផ្អែកតាមកំណើននៃការប្រើប្រាស់របស់អឺរ៉ុប តម្រូវឱ្យកម្ពុជាត្រូវមានទស្សនវិស័យរយៈពេលវែងក្នុងការជំរុញ និងបង្កើនការយល់ដឹងរបស់អតិថិជន អំពីគុណតម្លៃអាហារូបត្ថម្ភនៃគ្រាប់ស្វាយចន្ទី ស្របពេលដែលអតិថិជននៅអឺរ៉ុបកំពុងចូលចិត្តគ្រាប់ស្វាយចន្ទីឆៅនិងលីងដែលមានរសជាតិឈ្ងុយឆ្ងាញ់ជាងគ្រាប់ធញ្ញជាតិដទៃផ្សេងទៀត។ ដើម្បីបង្កើនភាពប្រកួតប្រជែង និងពិពិធកម្មផ្នែកសេដ្ឋកិច្ចដែលធានាបាននូវកំណើនខ្ពស់និងការបង្កើតការងារ កម្ពុជាចាំបាច់ត្រូវចាប់យកកាលានុវត្តភាពនេះ ដោយពង្រឹងនិងពង្រីកការកែច្នៃផលិតផលស្វាយចន្ទីឱ្យអស់លទ្ធភាព តាមរយៈការបង្កើតស្តង់ដាអនាម័យ និងការធានាបាននូវបរិមាណនិងគុណភាពដើម្បីផ្គត់ផ្គង់ទីផ្សារជាតិនិងអន្តរជាតិ។

[11] ប្រភពទិន្នន័យពី: សកម្មភាពការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០២០ និងទិសដៅអនុវត្តន៍បន្ត ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១

[12] របាយការណ៍ស្តីពី សកម្មភាពការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២

គោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ត្រូវបានរៀបចំនិងសម្រេចគោលដៅយ៉ាងមុតស្រួចឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ព្រមទាំងមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ជាពិសេសគឺស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ ដើម្បីសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍ដំណាំស្វាយចន្ទីប្រកបដោយនិរន្តរភាព គោលនយោបាយនេះផ្តោតលើយុទ្ធសាស្ត្រចម្បងចំនួន៣គឺ ការផលិត ការកែច្នៃ និងការនាំចេញ។

## ២. ចក្ខុវិស័យ

គោលនយោបាយជាតិស្តីពីស្វាយចន្ទីមានចក្ខុវិស័យអភិវឌ្ឍផលិតកម្ម ការកែច្នៃ និងទីផ្សារស្វាយចន្ទីឱ្យមានលក្ខណៈប្រកួតប្រជែងប្រកបដោយបរិយាបន្ន ធានានូវនិរន្តរភាព និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។

## ៣. គោលបំណងនិងគោលដៅ

គោលនយោបាយជាតិស្តីពីស្វាយចន្ទី មានគោលបំណងប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសផលិតនិងផ្គត់ផ្គង់ផលិតផលស្វាយចន្ទីដ៏សំខាន់មួយសម្រាប់បម្រើទីផ្សារក្នុងស្រុក តំបន់ និងពិភពលោក។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ គោលនយោបាយជាតិស្តីពីស្វាយចន្ទីបានដាក់ចេញនូវគោលដៅចម្បងចំនួន៣ ដូចខាងក្រោម៖

- លើកកម្ពស់ទិន្នផលនៃការផលិតនិងផលិតកម្ម ប្រកបដោយគុណភាពប្រកួតប្រជែង
- ជំរុញការធ្វើឧស្សាហូបនីយកម្មដើម្បីបង្កើនតម្លៃបន្ថែមលើការប្រមូលផលនិងការកែច្នៃអនុផលស្វាយចន្ទីឱ្យសម្រេចបាន២៥ភាគរយនៅឆ្នាំ២០២៧ និងយ៉ាងតិច៥០ភាគរយនៅឆ្នាំ២០៣២
- ជំរុញការនាំចេញ តាមរយៈការធ្វើពិពិធកម្មទីផ្សារ ការផ្សារភ្ជាប់អន្តរវិស័យក្នុងការនាំចេញ កិច្ចសម្រួលពាណិជ្ជកម្ម ការកាត់បន្ថយថ្លៃដើម និងការលើកកម្ពស់ឧត្តមភាពលើទីផ្សារ។

## ៤. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រគន្លឹះដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃគោលនយោបាយជាតិស្តីពីស្វាយចន្ទី ផ្តោតសំខាន់លើយុទ្ធសាស្ត្រចំនួន៣គឺ៖

### ៤.១. យុទ្ធសាស្ត្រនៃការផលិត

យុទ្ធសាស្ត្រនេះ ផ្តោតសំខាន់លើការលើកកម្ពស់ផលិតភាពនៃវិស័យស្វាយចន្ទី ដោយយកចិត្តទុកដាក់ជំរុញកែលម្អការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗប្រកបដោយនវានុវត្តន៍ ការអនុវត្តកសិកម្មល្អ កសិកម្មសរីរាង្គ

ការរៀបចំផែនការដាំដុះទៅតាមតម្រូវការទីផ្សារ ការកំណត់តំបន់ដាំដុះ ការកែលម្អការគ្រប់គ្រងនិងការប្រើប្រាស់ដី ការពង្រឹងការគ្រប់គ្រងនិងត្រួតពិនិត្យពូជដំណាំ ការកែលម្អប្រព័ន្ធស្រោចស្រព និងការប្រើប្រាស់យន្តូបនីយកម្មកសិកម្មនិងបច្ចេកវិទ្យាក្រោយប្រមូលផលឱ្យបានល្អប្រសើរ។ ដើម្បីរក្សាកំណើនឱ្យមានចីរភាពលើវិស័យស្វាយចន្ទី ចាំបាច់ត្រូវជំរុញឱ្យមានកំណើននៃការដាំដុះ ដោយប្រើប្រាស់ពូជដែលមានគុណភាពខ្ពស់(គ្រាប់ធំ) ធន់ទៅនឹងការបំផ្លាញពីសមាសភាពចង្រៃនិងការប្រែប្រួលអាកាសធាតុ និងមានកម្រិតសំណល់គីមីអប្បបរមាអនុលោមទៅតាមស្តង់ដារបស់ប្រទេសនាំចូល។

ចំពោះផែនការប្រមូលផលនិងកែច្នៃ ការគ្រប់គ្រងគុណភាពនិងការគ្រប់គ្រងហានិភ័យត្រូវមានគោលដៅកំណត់ជាមុនក្នុងការសហការអនុវត្តដូចជា កម្មវិធីដាំដុះ វិធីប្រមូលផល និងថ្លៃដើមផលិតកម្ម។ តម្រូវការទីផ្សារនិងខ្សែច្រវាក់ផ្គត់ផ្គង់ ត្រូវមានភាពបន្សីគ្នា ដោយភាគីពាក់ព័ន្ធ ដូចជាកសិករ អ្នកកែច្នៃ និងអ្នកនាំចេញ ត្រូវបានលើកទឹកចិត្តឱ្យរៀបចំផែនការនិងសហការអនុវត្តតាមផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជនជាមួយដៃគូអភិវឌ្ឍនានាត្រូវបន្តសហការ ដើម្បីអនុវត្តការបណ្តុះបណ្តាលសមត្ថភាព ដល់មន្ត្រីជំនាញ ផលិតករ( ខ្នាតតូច មធ្យម និងខ្នាតធំ ) និងសហគមន៍កសិកម្មឱ្យយល់ដឹងជាសាធារណៈ អំពីការអភិវឌ្ឍវិស័យកសិកម្ម ព្រមទាំងលើកកម្ពស់ការវិនិយោគពីវិស័យឯកជន លើខ្សែច្រវាក់ផលិតកម្មកសិកម្មតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ឱ្យមានលក្ខណៈប្រទាក់ក្រឡាក្នុងការស្វែងរកទីផ្សារថ្មីៗបន្ថែមសម្រាប់ផលិតផលស្វាយចន្ទី។

**៤.២- យុទ្ធសាស្ត្រនៃការកែច្នៃ**

យុទ្ធសាស្ត្រនេះគឺជាចំណុចសំខាន់ក្នុងការធ្វើពិពិធកម្មមុខទំនិញ សម្រាប់បង្កើនតម្លៃបន្ថែមដល់ផលិតផលស្វាយចន្ទី ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយប្រែក្លាយពីកសិករទៅជាកសិពាណិជ្ជករ តាមរយៈការបង្កើនផលិតភាព ការកាត់បន្ថយថ្លៃដើមផលិតកម្ម ការអនុវត្តបច្ចេកវិទ្យាទំនើបសមស្រប និងផលិតផលមានគុណភាពប្រកបដោយឧត្តមភាពប្រកួតប្រជែង ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារទាំងក្នុងនិងក្រៅប្រទេស និងជំរុញសហគមន៍កសិកម្ម ឱ្យក្លាយជាមូលដ្ឋានផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់បម្រើនិងបង្កើនកសិឧស្សាហកម្មកែច្នៃ។ យុទ្ធសាស្ត្រនេះក៏បានផ្តោតសំខាន់ទៅលើការអនុវត្តឱ្យស្របតាមខ្សែច្រវាក់ផលិតកម្មស្វាយចន្ទី ដើម្បីបង្កើនតម្លៃបន្ថែម ដែលមានជាអាទិ៍៖

- ការជំរុញក្បៀរគរវិនិយោគ ជំនួយបច្ចេកទេស និងធនធានទាំងក្នុងនិងក្រៅប្រទេស ដើម្បីជំរុញវិស័យស្វាយចន្ទីកម្ពុជាឱ្យមាននិរន្តរភាពនិងអភិវឌ្ឍន៍
- បង្កើនតម្លៃបន្ថែមក្រោយការប្រមូលផលតាមរយៈការសម្ងួត វេចខ្ចប់ និងការធ្វើចំណាត់ថ្នាក់គ្រាប់តាមការកែច្នៃបឋម ការបកសម្បក និងការធ្វើចំណាត់ថ្នាក់សម្រាប់ផ្គត់ផ្គង់ដល់អ្នកនាំចូលនិងអ្នកផលិតនៅក្នុងទីផ្សារគោលដៅដែលមានតម្លៃខ្ពស់

- បង្កើនតម្លៃបន្ថែមតាមរយៈការបំពេញនិងផ្គត់ផ្គង់ដល់ផលិតកម្មកែច្នៃឱ្យទៅជាផលិតផលសម្រេច ដូចជាផលិតផលអាហារសម្រន់និងគ្រឿងផ្សំក្នុងផលិតផលផ្សេងទៀត
- បង្កើនតម្លៃបន្ថែមតាមការផលិតផលិតផលកែច្នៃផ្សេងៗ សម្រាប់ផ្គត់ផ្គង់ទៅឱ្យអ្នកលក់រាយដែលភាគច្រើននៅលើទីផ្សារគោលដៅ។

តាមការសិក្សាកន្លងមកបានបង្ហាញថា ឧស្សាហកម្មកែច្នៃស្វាយចន្ទីកម្ពុជា ត្រូវផ្សារភ្ជាប់ជាមួយនឹងវិស័យពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើឱ្យសេដ្ឋកិច្ចមូលដ្ឋានមានចរន្តរស់រវើក ដែលបង្កើតបាននូវគុណតម្លៃបន្ថែមតាមរយៈការកែច្នៃ ដូចជាគ្រាប់ស្វាយចន្ទីឆ្អិន ទឹកខ្មេះស្វាយចន្ទី គំណាប់ស្វាយចន្ទី ភេសជ្ជៈ ប្រេងស្វាយចន្ទី ទឹកខ្ទិះស្វាយចន្ទី ទឹកដោះគោជូរស្វាយចន្ទី ទឹកក្រែមស្វាយចន្ទី ប៊ឺស្វាយចន្ទី ការ៉េមស្វាយចន្ទី ស្រាស្វាយចន្ទី និងប្រហុកម៉ាស្វាយចន្ទីជាដើម។ គ្រាប់ស្វាយចន្ទីលីងនិងឆៅមានប្រជាប្រិយភាពជាងគ្រាប់ធញ្ញជាតិដទៃទៀត ព្រោះវាជាអាហារដែលមានរសជាតិឆ្ងាញ់និងជាអាហារសុខភាព។

### ៤.៣. យុទ្ធសាស្ត្រនៃការនាំចេញ

ស្វាយចន្ទីកម្ពុជា ជាប្រភេទដំណាំកសិឧស្សាហកម្មបែបប្រពៃណី ដែលអាចផ្គត់ផ្គង់ដល់ទីផ្សារទាំងក្នុងស្រុកនិងពិភពលោក ជាដំណាំដែលមានសក្តានុពល ជាអាហារូបត្ថម្ភដ៏សំខាន់ ជាវត្ថុធាតុដើមសម្រាប់ការផលិតជាផលិតផលផ្សេងៗ និងមានសារប្រយោជន៍ជាច្រើនទៀត។ ដើម្បីឆ្លើយតបបាន ទៅតាមបត់ថ្មីនៃការប្រកួតប្រជែង និងអាចពង្រឹងបាននូវឧត្តមភាពទីផ្សារស្វាយចន្ទីកម្ពុជា គោលនយោបាយជាតិស្តីពីស្វាយចន្ទី បានដាក់ចេញនូវយុទ្ធសាស្ត្រទីផ្សារនិងការនាំចេញសម្រាប់អនុវត្ត ដូចខាងក្រោម៖

- ការពង្រីកសៅលភាពកសិពាណិជ្ជកម្មស្របតាមតម្រូវការទីផ្សារទាំងក្នុងនិងក្រៅប្រទេស តាមរយៈកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន
- ការជំរុញលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលស្វាយចន្ទីក្នុងស្រុក តាមរយៈការរៀបចំវេទិកាជំនួបធុរកិច្ចនិងវិនិយោគរវាងអ្នកផលិត អ្នកបញ្ជាទិញ និងអ្នកប្រើប្រាស់ផលិតផលស្វាយចន្ទី ដើម្បីជំរុញការនាំចេញនៅនឹងកន្លែង
- ការសម្រួលពាណិជ្ជកម្មក្នុងការនាំចេញផលិតផលស្វាយចន្ទី តាមរយៈការថែរក្សាទីផ្សារចាស់ ការចរចាបើកទីផ្សារគោលដៅថ្មីបន្ថែមតាមគ្រប់យន្តការទាំងក្នុងតំបន់ និងពិភពលោក ការអភិវឌ្ឍកែលម្អប្រព័ន្ធភស្តុភារកម្ម ការធ្វើសុខដុមនីយកម្មប្រព័ន្ធបញ្ជរតែមួយជាតិ
- ការកែលម្អនីតិវិធីដែលមានស្រាប់ ការបង្កើតយន្តការ និងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ សំដៅជំរុញដល់ការនាំចេញ និងទីផ្សារឱ្យមានប្រសិទ្ធភាព រួមទាំងបែបបទត្រួតពិនិត្យទំនិញនាំចេញ នាំចូល។ ការផ្សព្វផ្សាយព័ត៌មានអំពីវិធានពាណិជ្ជកម្ម ព្រមទាំងតភ្ជាប់ទំនាក់ទំនងដល់សហគមន៍អ្នកផលិត ពាណិជ្ជករ

អ្នកនាំចេញ និងអ្នកពាក់ព័ន្ធដទៃទៀតតាមគ្រប់មធ្យោបាយ តាមរយៈព្រឹត្តិការណ៍ពាណិជ្ជកម្ម វេទិកាជំនួបពាណិជ្ជកម្ម យុទ្ធនាការប្រើប្រាស់ផលិតផលខ្មែរ និងម៉ាកពាណិជ្ជកម្មជាដើម
- ការបង្កើនផលិតភាពដំណាំស្វាយចន្ទីប្រកបដោយការប្រកួតប្រជែង កាត់បន្ថយថ្លៃដើមផលិតកម្មនៃផលិតផលស្វាយចន្ទី ដោយធានាបាននូវគុណភាពនិងស្តង់ដាស្របតាមតម្រូវការទីផ្សារ
- ជំរុញការនាំចេញផលិតផលស្វាយចន្ទី តាមរយៈយន្តការកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនិងពហុភាគី។

## ៥. ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ផែនការសកម្មភាពត្រូវអនុវត្ត រួមមាន៖

### ៥.១. ការបង្កើតយន្តការ

ដើម្បីនិរន្តរភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ចាំបាច់ត្រូវប្រមូលផ្តុំតម្រង់ទិសធនធានមនុស្ស និងកៀរគរហិរញ្ញវត្ថុឱ្យស្របតាមការចាំបាច់នៃទំហំការងារប្រកបដោយតម្លាភាព សង្គតិភាព និងភ្ជាប់ទំនាក់ទំនងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍ តាមរយៈការបង្កើតយន្តការដូចខាងក្រោម៖

៥.១.១. បង្កើតគណៈកម្មការអន្តរក្រសួងតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ គណៈកម្មការនេះមានសមាសភាពមកពីក្រសួងស្ថាប័នពាក់ព័ន្ធនិងមានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

៥.១.២. ពង្រឹងសហព័ន្ធស្វាយចន្ទី ដើម្បីប្រមូលកៀរគរកសិករ ផលិតករ និងភាគីពាក់ព័ន្ធទាំងអស់ដែលនឹងក្លាយជាមូលដ្ឋានផ្គត់ផ្គង់វត្ថុធាតុដើម ស្ថិតនៅក្រោមដំបូលតែមួយ សម្រាប់បម្រើឱ្យកសិឧស្សាហកម្មកែច្នៃ និងមានចក្ខុវិស័យរួមគ្នាក្នុងការសម្រេចនូវគោលដៅតែមួយ គឺអភិវឌ្ឍន៍វិស័យស្វាយចន្ទីកម្ពុជាប្រកបដោយនិរន្តរភាព។

៥.១.៣. ពង្រឹងមជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ ដើម្បីអនុវត្តផលិតកម្មនិងគ្រប់គ្រងក្រោយការប្រមូលផលស្វាយចន្ទីតាមតំបន់ដែលមានសក្តានុពល ដើម្បីផ្សារភ្ជាប់រវាងផលិតករជាមួយតួអង្គនៃខ្សែច្រវាក់តម្លៃស្វាយចន្ទីនិងស្ថាប័នពាក់ព័ន្ធ។

៥.១.៤- ពង្រឹងសមត្ថភាពរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាល័យជាតិកសិកម្ម និងមន្ទីរពិសោធន៍ផ្សេងៗទៀត ដើម្បីស្រាវជ្រាវពូជស្វាយចន្ទីដែលមានគ្រាប់ធំ គុណភាពខ្ពស់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

**៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត**

ដើម្បីឱ្យគោលនយោបាយជាតិស្ដីពីស្វាយចន្ទី អនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព ក្រសួង ស្ថាប័ន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យស្វាយចន្ទី ស្របតាមតម្រូវការចាំបាច់។

**៥.៣- ការគាំទ្រហិរញ្ញវត្ថុ**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារសហគ្រាសធុនតូចនិងមធ្យម ត្រូវពិនិត្យលទ្ធភាពក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការផ្ដល់ហិរញ្ញប្បទាន ស្របតាមស្មារតីនៃគោលនយោបាយជាតិស្ដីពីស្វាយចន្ទី។ បន្ថែមពីនេះ ប្រភពហិរញ្ញប្បទាន និងជំនួយគាំទ្រដទៃទៀត អាចស្វែងរកពីដៃគូអភិវឌ្ឍ វិស័យឯកជន ព្រមទាំងថវិកាដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត។

**៥.៤- ការអភិវឌ្ឍធនធានមនុស្ស**

ដើម្បីអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យស្វាយចន្ទី វិទ្យាស្ថានស្តង់ដាកម្ពុជា មជ្ឈមណ្ឌលផលិតភាពជាតិកម្ពុជា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម គ្រឹះស្ថានបណ្ដុះបណ្ដាលជាតិកសិកម្ម អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់កម្មវិធីបណ្ដុះបណ្ដាល និងស្រាវជ្រាវ គាំទ្រដល់វិស័យស្វាយចន្ទី និងរៀបចំនីតិវិធី ដើម្បីកំណត់គុណភាពឱ្យស្របតាមស្តង់ដា បទដ្ឋានជាតិនិងអន្តរជាតិ រួមទាំងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ការចូលរួមព្រឹត្តិការណ៍នានា និងទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស។

**៥.៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ**

៥.៥.១- ជំរុញការបង្កើតបរិយាកាសអំណោយផលសម្រាប់ការដាំដុះ ដោយកសាង កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាប្រព័ន្ធធារាសាស្ត្រ អគ្គិសនី និងប្រព័ន្ធបង្ហូរទឹកកខ្វក់ ជាដើម។

៥.៥.២- ជំរុញការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងរក្សាទុកពីកសិដ្ឋានតភ្ជាប់ទៅឃ្លាំងស្តុកនិងតំបន់កែច្នៃរួមមាន ផ្លូវលំ ផ្លូវទឹក ផ្លូវថ្នល់ និងស្ពាន។

៥.៥.៣. ពិនិត្យលទ្ធភាពក្នុងការកសាងនិងកែលម្អផ្លូវដឹកជញ្ជូនយុទ្ធសាស្ត្រ ដែលកាត់បន្ថយចម្ងាយដឹកជញ្ជូនពីតំបន់កែច្នៃ/រោងចក្រ ទៅកាន់កំពង់ផែឬច្រកនាំចេញ (ផ្លូវជាតិ ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស) និងពង្រឹងប្រសិទ្ធភាពប្រព័ន្ធកស្តុភារកម្ម។

៥.៥.៤. ជំរុញការកែច្នៃសំណល់ពីផលិតផលស្វាយចន្ទី ទៅជាពហុផលិតផលដែលមានអត្ថប្រយោជន៍ ដោយអនុវត្តច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងផលប៉ះពាល់បរិស្ថានឱ្យបានប្រសើរ។

## ៥.៦. ដំណើរការអនុវត្តគម្រោង

គោលនយោបាយនេះ ត្រូវអនុវត្តឱ្យស្របជាមួយនឹងយុទ្ធសាស្ត្រជាតិនិងគោលនយោបាយនានាបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីអភិវឌ្ឍវិស័យស្វាយចន្ទីប្រកបដោយប្រសិទ្ធភាព។

ផែនការនៃការអនុវត្តគោលនយោបាយនេះ ត្រូវបានបែងចែកទៅតាមចង្កោមសកម្មភាពដូចខាងក្រោម៖

## ៥.៦.១. ផលិតកម្មដំណាំស្វាយចន្ទី

៥.៦.១.១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្សព្វផ្សាយរបកគំហើញថ្មីៗដល់កសិករតាមរយៈគេហទំព័រព័ត៌មានរបស់មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ឬប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គម ដោយរៀបចំគេហទំព័រនេះជាវេទិកាមួយដែលកសិករអាចចូលរួមចែករំលែកបទពិសោធ និងគំនិតផ្ទាល់ខ្លួន។

៥.៦.១.២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបន្តសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រលើពូជស្វាយចន្ទី ជាពិសេសពូជថ្មីៗដែលស្របតាមប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជានិងតម្រូវការទីផ្សារគោលដៅ។

៥.៦.១.៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តការកសាងនិងកែលម្អវិធីសាស្ត្រនៃការវាស់ស្ទង់ទិន្នផលប្រចាំឆ្នាំផ្អែកលើទិន្នន័យស្ទាបស្ទង់ចុងក្រោយបំផុតដែលមានស្រាប់ ដូចជាទិន្នផលនៅនឹងចម្ការ ថ្លៃដើមនៃការផលិត រួមទាំងការប្រើប្រាស់ធាតុចូលកសិកម្ម កម្រិតនៃការវិនិយោគ អាយុដើមស្វាយចន្ទី ពូជដែលបានដាំ ការដាំដុះថ្មី និងសមាសភាពចង្រៃ ដើម្បីបង្កើនផលិតកម្មស្វាយចន្ទី ព្រមទាំងគណនាផ្ទៀងផ្ទាត់ទិន្នផល និងកំណត់សក្តានុពលសម្រាប់ការកែលម្អ។

៥.៦.១.៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ត្រូវពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងឡាយដែលមានស្រាប់ និងវាយតម្លៃហានិភ័យលើបរិស្ថាន ក្នុងការគ្រប់គ្រងនូវវត្ថុធាតុដើមកសិកម្ម ជាពិសេសថ្នាំពុលកសិកម្មក្នុងការបង្កើនប្រសិទ្ធភាពផលិតផលស្វាយចន្ទីស្របទៅតាមលក្ខខណ្ឌស្តង់ដាបច្ចេកទេស។

៥.៦.១.៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើនផលិតភាពផលិតកម្ម និងការពារសុវត្ថិភាពកសិករនិងកម្មករនៅតាមកសិដ្ឋាន តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសទាំងទ្រឹស្តីនិងការអនុវត្តជាក់ស្តែង ដើម្បីកែលម្អគុណភាពសេវា ការអនុវត្តបច្ចេកទេសកសិកម្មល្អ និងកសិកម្មសរីរាង្គឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពនៅក្នុងវិស័យស្វាយចន្ទី។

៥.៦.១.៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ត្រូវណែនាំឱ្យមានការចងក្រងក្រុមផលិត ព្រមទាំងសិក្សាប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ ដើម្បីកំណត់អត្តសញ្ញាណប្រភពផលិតផលស្វាយចន្ទីកម្ពុជានៅលើទីផ្សារ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវណែនាំនិងសម្របសម្រួលក្នុងការបង្កើតសហគមន៍កសិកម្មលើដំណាំស្វាយចន្ទីនិងពង្រឹងសហគមន៍កសិកម្មឱ្យមានដំណើរការល្អ។

៥.៦.១.៧. ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្មត្រូវសហការសម្របសម្រួលក្នុងការបង្កើតសមាគមស្វាយចន្ទីនិងសហព័ន្ធស្វាយចន្ទី។

៥.៦.១.៨. ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពង្រឹងអនុវត្តន៍ការធ្វើកសិកម្មតាមកិច្ចសន្យា ដើម្បីធានាដល់ខ្សែច្រវាក់ផ្គត់ផ្គង់ ដោយបង្កើនតម្លៃបន្ថែមទាំងក្នុងនិងក្រោយរដូវប្រមូលផល តាមរយៈយន្តការផ្សារភ្ជាប់រវាងសមាគម សហគមន៍កសិកម្ម ក្រុមកសិករនិងអ្នកកែច្នៃក្នុងស្រុក សម្រាប់ធ្វើពាណិជ្ជូបនីយកម្មនៅកម្ពុជា។

៥.៦.១.៩. ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពង្រឹងកេរ្តិ៍ឈ្មោះលើផលិតផលស្វាយចន្ទី តាមរយៈការពង្រឹងគុណភាព សេជាតិ និងការប្រើប្រាស់សារធាតុគីមីឱ្យត្រូវតាមបទដ្ឋានបច្ចេកទេសក្នុងផលិតកម្ម។

៥.៦.១.១០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវត្រួតពិនិត្យនិងជំរុញការអនុវត្តកសិកម្មល្អ(CamGAP)និងកសិកម្មសរីរាង្គ សម្រាប់ដំណាំស្វាយចន្ទី។

៥.៦.១.១១. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារសហគ្រាសធុនតូចនិងមធ្យម ត្រូវបង្កើតកញ្ចប់ថវិកាសម្រាប់ជួយអន្តរាគមន៍ដល់ការលំបាករបស់កសិករនិងរោងចក្រកែច្នៃ នៅពេលមានគ្រោះធម្មជាតិ ជំងឺឆ្លងកាចសាហាវ ការបិទច្រកព្រំដែន ការអាក់រអួលនៃទីផ្សារ និងភាពជន់ជោរនៅរដូវប្រមូលផល។

៥.៦.១.១២. ធនាគារជាតិនៃកម្ពុជា លើកទឹកចិត្តឱ្យធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ បង្កើតផលិតផលឥណទានកសិកម្ម ឬកែសម្រួលផលិតផលមានស្រាប់ ឱ្យមានលក្ខខណ្ឌងាយស្រួលនិងអត្រាការប្រាក់ទាប។

៥.៦.១.១៣. ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវពិនិត្យលទ្ធភាពក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ និងប្រភពទឹកផ្សេងៗ សម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ទឹកលើដំណាំស្វាយចន្ទី។

៥.៦.១.១៤. អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ត្រូវកំណត់អាទិភាពលើផែនការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះសម្រាប់ចម្ការស្វាយចន្ទី។

៥.៦.១.១៥. ក្រសួងអភិវឌ្ឍន៍ជនបទនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលវិស័យស្វាយចន្ទីក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ខ្លួន និងសហការជាមួយសហគមន៍មូលដ្ឋាន និងដៃគូអភិវឌ្ឍ សម្រាប់ស្តារបនានិងកែលម្អផ្លូវទៅកសិដ្ឋាន តាមលទ្ធភាពប្រមូលផ្តុំមូលនិធិបដិភាគ។

**៥.៦.២. ការកែច្នៃផលិតផលស្វាយចន្ទី**

៥.៦.២.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវលើកទឹកចិត្តវិស័យឯកជនឱ្យវិនិយោគកែច្នៃផលិតផលស្វាយចន្ទី សម្រាប់តម្រូវការទីផ្សារក្នុងស្រុក និងការនាំចេញ។

៥.៦.២.២. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវជំរុញឱ្យមានរោងចក្រកែច្នៃផលិតផលស្វាយចន្ទី ដើម្បីអភិវឌ្ឍសមត្ថភាពផលិតកម្មស្វាយចន្ទី ជាមួយនឹងការផ្ទេរបច្ចេកវិទ្យាឧស្សាហកម្មកែច្នៃ ដើម្បីអភិវឌ្ឍសមត្ថភាពផលិតកម្មស្វាយចន្ទី សម្រាប់ផលិតជាម្ហូបអាហារនិងកែច្នៃកាកសំណល់ស្វាយចន្ទី។

៥.៦.២.៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំគោលការណ៍ណែនាំនិងផ្សព្វផ្សាយដល់កសិករនិងម្ចាស់កសិដ្ឋានអំពីរបៀបសម្ងួតនិងវិធីថែរក្សាទុកគ្រាប់ស្វាយចន្ទីឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេស ដើម្បីធានាបានផលិតផលស្វាយចន្ទីដែលមានគុណភាពល្អនិងសុវត្ថិភាព។

៥.៦.២.៤. ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នពាក់ព័ន្ធ ត្រូវសិក្សាពីផលចំណេញសេដ្ឋកិច្ច និងលើកទឹកចិត្តជំរុញឱ្យវិស័យឯកជនបង្កើតតំបន់កែច្នៃស្វាយចន្ទី ដែលជាតំបន់មួយព័ទ្ធទៅដោយចម្ការស្វាយចន្ទី ឬនៅសួនកសិឧស្សាហកម្មក្នុងខេត្តដែលមានសក្តានុពលកសិកម្ម សម្រាប់ផ្គត់ផ្គង់ក្នុងខ្សែច្រវាក់ផលិតកម្មស្វាយចន្ទីក្នុងទីតាំងតែមួយ ហើយការបង្កើតតំបន់កែច្នៃនេះ អាចបង្កើនតម្លៃបន្ថែមច្រើនដល់សេដ្ឋកិច្ចជនបទ។

៥.៦.២.៥. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវលើកទឹកចិត្ត ការកែច្នៃ និងគ្រប់គ្រងផលិតផលស្វាយចន្ទី សម្រាប់ការប្រើប្រាស់ជាផលិតផលសម្រេចឬជាវត្ថុធាតុដើម សម្រាប់ផលិតផលិតផលផ្សេងៗ។

៥.៦.២.៦. ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់រោងចក្រកែច្នៃស្វាយចន្ទី ដើម្បីគ្រប់គ្រងកាកសំណល់ឱ្យមានប្រសិទ្ធភាពខ្ពស់ ទប់ស្កាត់ផលប៉ះពាល់បរិស្ថាន និងបង្កើនតម្លៃបន្ថែមពីការប្រើប្រាស់សំណល់ពីផលិតកម្មកែច្នៃស្វាយចន្ទី។

៥.៦.២.៧. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវសិក្សានិងបង្កើតស្តង់ដាពាក់ព័ន្ធនឹងផលិតផលស្វាយចន្ទី រៀបចំនីតិវិធីទទួលស្គាល់និងអនុវត្តស្តង់ដាផលិតផលស្វាយចន្ទីតាមតម្រូវការរបស់ប្រទេសនាំចូល ដើម្បីធានាគុណភាពនិងនិរន្តរភាពនៃការកែច្នៃស្វាយចន្ទីកម្ពុជា តាមរយៈការផ្តល់ការគាំទ្របច្ចេកទេសនិងការកសាងសមត្ថភាពដល់អ្នកកែច្នៃ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម។

៥.៦.២.៨. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវណែនាំនិងជួយសម្របសម្រួលដល់សហគ្រាសនិងរោងចក្រកែច្នៃស្វាយចន្ទី សម្រាប់ការលើកកម្ពស់ផលិតភាពការនាំចេញ ធានាគុណភាពនិងសុវត្ថិភាពក្នុងកម្រិតអប្បបរមាស្របតាមប្រព័ន្ធគ្រប់គ្រងគុណភាពឬស្តង់ដាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារអន្តរជាតិ ឬប្រព័ន្ធសមមូលនៅនឹងកន្លែង ដែលត្រូវបានបញ្ជាក់ដោយអង្គភាពចេញវិញ្ញាបនបត្រកម្មដែលមានការទទួលស្គាល់។

៥.៦.២.៩. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្ត តាមរយៈការលើកលែងឬកាត់បន្ថយពន្ធលើប្រាក់ចំណេញ ពន្ធលើផលិតផលកែច្នៃពីស្វាយចន្ទី និងអាករលើតម្លៃបន្ថែមជូនដល់ប្រតិបត្តិករស្វាយចន្ទីស្របច្បាប់ដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់កសិករ។

៥.៦.២.១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលទ្ធភាពនិងផ្តល់ការលើកទឹកចិត្តដែលចាំបាច់ដល់វិស័យឯកជន ដូចជាការកសាងឃ្លាំងស្តុកទុកគ្រាប់ស្វាយចន្ទីនៅទីតាំងយុទ្ធសាស្ត្រសំខាន់ៗ សម្រាប់ស្តុកផលិតផលស្វាយចន្ទីដើម្បីកែច្នៃជាដើម។

៥.៦.២.១១. ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកៀគរវិនិយោគិនដើម្បីកសាងទីលានឬឡសម្ងួត និងឃ្លាំងស្តុកនៅទីតាំងយុទ្ធសាស្ត្រសំខាន់ៗ សម្រាប់គ្រប់គ្រងការប្រមូលផលនិងស្តុកទុកផលិតផលស្វាយចន្ទីយកទៅកែច្នៃ។

៥.៦.២.១២. ក្រសួងរ៉ែនិងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវពិនិត្យលទ្ធភាពរៀបចំសម្របសម្រួលបន្ថយថ្លៃអគ្គិសនីជូនដល់អ្នកប្រើប្រាស់ក្នុងវិស័យស្វាយចន្ទី។

**៥.៦.៣. ទីផ្សារនិងការនាំចេញស្វាយចន្ទី**

៥.៦.៣.១. ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពង្រឹងសេវាផ្តល់ព័ត៌មាននិងទិន្នន័យប្រមូលផ្តុំទីផ្សារ ជូនកសិករនិងសាធារណជនតាមប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីងាយស្រួលតាមដានស្ថានភាពទីផ្សារ។

៥.៦.៣.២. ក្រសួងពាណិជ្ជកម្ម សម្របសម្រួលក្នុងការបង្កើតសមាគមឬសហព័ន្ធពាណិជ្ជកម្មស្វាយចន្ទី ដើម្បីប្រមូលផ្តុំវិស័យឯកជន អ្នកនាំចេញ អ្នកកែច្នៃ និងប្រតិបត្តិករពាក់ព័ន្ធនឹងអាជីវកម្មស្វាយចន្ទី។

៥.៦.៣.៣. ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យមើលនិន្នាការទីផ្សារ ការប្រកួតប្រជែងនៅក្នុងតំបន់ និងខ្សែច្រវាក់តម្លៃ ដើម្បីជំរុញការអភិវឌ្ឍវិស័យស្វាយចន្ទីប្រកបដោយសង្គតិភាពនិងបរិយាបន្ន។

៥.៦.៣.៤. ក្រសួងពាណិជ្ជកម្ម ត្រូវបន្តការចរចាជាមួយប្រទេសគោលដៅនាំចេញ លើការលើកលែងពន្ធឬការកាត់បន្ថយពន្ធ ការកំណត់កូតា និងកិច្ចសម្រួលពាណិជ្ជកម្ម ពិសេសការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវយន្តការច្រកចេញចូលតែមួយ។

៥.៦.៣.៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជំរុញការចរចាជាមួយប្រទេសគោលដៅលើការសម្រួលលើការអនុវត្តវិធានអនាម័យនិងភូតគាមអនាម័យ និងកសាងសមត្ថភាពអ្នកនាំចេញកម្ពុជា និងភាគីពាក់ព័ន្ធឱ្យមានលទ្ធភាពអនុវត្តតាមអនុលោមភាពនៃអនាម័យនិងភូតគាមអនាម័យ តាមរយៈការលើកទឹកចិត្ត និងបើកចំហដល់វិស័យឯកជន ក្នុងការចូលរួមផ្តល់សេវាកម្មវិធានអនាម័យនិងភូតគាមអនាម័យ។

៥.៦.៣.៦. ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវជំរុញនិងផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាក់ស្លាកសញ្ញាពាណិជ្ជកម្ម និងវេចខ្ចប់ប្រកបដោយគុណភាពនិងស្តង់ដា។

៥.៦.៣.៧. ក្រសួងពាណិជ្ជកម្ម ត្រូវជំរុញការកសាងកេរ្តិ៍ឈ្មោះម៉ាកល្អ លើផលិតផលនេះតាមគ្រប់មធ្យោបាយ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបង្កើនភាពប្រកួតប្រជែងលើទីផ្សារ។

៥.៦.៣.៨. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវសម្របសម្រួលយន្តការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលម្ហូបអាហារ និងពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ស្របតាមបទដ្ឋានអន្តរជាតិ។ ដំណើរការនៃមន្ទីរពិសោធន៍នេះ អាចមានការចូលរួមវិនិយោគជាដៃគូរវាងរដ្ឋនិងឯកជន។

៥.៦.៣.៩. ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងធនាគារជាតិនៃកម្ពុជា ត្រូវជំរុញនិងសម្របសម្រួលបង្កើតបច្ចេកវិទ្យាឌីជីថលថ្មីៗ សម្រាប់ប្រតិបត្តិការធុរកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក។

៥.៦.៣.១០. ក្រសួងពាណិជ្ជកម្ម ត្រូវបង្កើតយន្តការឌីជីថលនិងបច្ចេកទេសថ្មីៗ ក្នុងការផ្សព្វផ្សាយកម្មវិធីស្វែងរកទីផ្សារ ដែលមានប្រភពច្បាស់លាស់ជាទំនុកចិត្តដល់អ្នកលក់និងអ្នកទិញ។

៥.៦.៣.១១. ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំវេទិកាធុរកិច្ចស្តីពីស្វាយចន្ទី ដើម្បីលើកកម្ពស់ផលិតផលស្វាយចន្ទីរបស់កម្ពុជា និងផ្សារភ្ជាប់វិស័យឯកជនទៅនឹងបណ្តាញធុរកិច្ចអន្តរជាតិ។

៥.៦.៣.១២. ក្រសួងពាណិជ្ជកម្ម ត្រូវជំរុញយុទ្ធនាការប្រើប្រាស់ផលិតផលស្វាយចន្ទីក្នុងស្រុក។

៥.៦.៣.១៣. ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជំរុញបង្កើតទីផ្សារកសិទេសចរណ៍លើផលិតផលស្វាយចន្ទីនៅនឹងកន្លែង។

៥.៦.៣.១៤. ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវបន្តសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ សម្រាប់តភ្ជាប់រោងចក្រ សហគ្រាស តំបន់សេដ្ឋកិច្ចពិសេស ទៅកំពង់ផែនិងមាត់ច្រកនាំចេញ។

៥.៦.៣.១៥. ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួលដល់នីតិវិធីនាំចេញ ដើម្បីកាត់បន្ថយថ្លៃដើម និងបង្កើនសមត្ថភាពប្រកួតប្រជែងផលិតផលស្វាយចន្ទីកម្ពុជា។

៥.៦.៣.១៦. ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពិនិត្យលទ្ធភាពកាត់បន្ថយកម្រៃសេវា ការបំពេញបែបបទដោយរលូននិងឆាប់រហ័ស ព្រមទាំងពិនិត្យលទ្ធភាពក្នុងការកសាងឃ្លាំងស្តុកតាមស្តង់ដារក្សាទុកសម្រាប់រាល់ផលិតផលកសិកម្ម។

## ៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទីឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យ តាមដាន វាយតម្លៃ និងសំណើកែលម្អការអនុវត្តដោយផ្តោតលើ៖

- ការបង្កើតគណៈកម្មការអន្តរក្រសួងមានតួនាទីតាមដាននិងវាយតម្លៃការអនុវត្តដោយផ្ទៀងផ្ទាត់គោលដៅ និងផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីស្វាយចន្ទី
- កំណត់សូចនាករវាស់វែងលទ្ធផលអនុវត្តនៃផែនការសកម្មភាព
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃគោលនយោបាយជាតិស្តីពីស្វាយចន្ទីដើម្បីឱ្យមានសង្គតិភាពនិងតម្រែតម្រង់គោលនយោបាយនេះ ឱ្យស្របគ្នាជាមួយគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធដទៃទៀត
- ការបង្កើតយន្តការដើម្បីប្រមូលព័ត៌មាន តាមដាន ត្រួតពិនិត្យ កែតម្រូវ និងរៀបចំរបាយការណ៍វាយតម្លៃលើការអនុវត្តគោលនយោបាយនេះ ព្រមទាំងលើកទិសដៅអនុវត្តបន្ត។

## ៧. សេចក្តីសន្និដ្ឋាន

ដំណាំស្វាយចន្ទីត្រូវបានចាត់ទុកជាដំណាំអាទិភាពមួយក្នុងចំណោមដំណាំសក្តានុពលផ្សេងៗទៀត ដែលបានផ្តល់នូវប្រភពចំណូលដ៏សំខាន់ និងបានចូលរួមចំណែកក្នុងកំណើនផលទិន្នផលសរុប ផលិតផល

ស្វាយចន្ទីកម្ពុជា មានបរិមាណច្រើនគួរឱ្យកត់សម្គាល់ ដែលភាគច្រើនផលិតផលស្វាយចន្ទីមិនទាន់កែច្នៃត្រូវបាននាំចេញទៅប្រទេសជិតខាង ដើម្បីកែច្នៃនិងបន្តនាំចេញទៅកាន់ប្រទេសដទៃទៀត។ ការនាំចេញផលិតផលស្វាយចន្ទីមិនទាន់កែច្នៃ បានធ្វើឱ្យកម្ពុជាបាត់បង់ការងារនិងតម្លៃបន្ថែមជាច្រើន។ ក្នុងន័យនេះរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីស្វាយចន្ទីនេះឡើង ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា ដោយលើកកម្ពស់ផលិតកម្មនិងផលិតភាពប្រកបដោយភាពប្រកួតប្រជែងទាំងទិន្នផលនិងគុណភាព ការធ្វើពិពិធកម្ម ការកែច្នៃ ការនាំចេញ និងការបង្កើនតម្លៃបន្ថែមដល់ភាគីពាក់ព័ន្ធក្នុងខ្សែច្រវាក់តម្លៃ សំដៅជួយគាំទ្រដល់តួអង្គដែលមានស្រាប់ និងទាក់ទាញការវិនិយោគបន្ថែម ព្រមទាំងការរក្សាទីផ្សារចាស់និងការស្វែងរកទីផ្សារថ្មីប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ដែលបានកំណត់នៅក្នុងចក្ខុវិស័យច្បាស់លាស់ប្រកបដោយភាពជោគជ័យ គឺជាការចាប់យកកាលានុវត្តភាពប្រកួតប្រជែងនៅក្នុងទីផ្សារ តាមរយៈការនាំចេញផលិតផលស្វាយចន្ទីកម្ពុជាទៅកាន់ទីផ្សារក្នុងតំបន់និងពិភពលោក ដោយកាត់បន្ថយការនាំចេញស្វាយចន្ទីមិនទាន់កែច្នៃ ដើម្បីបង្កើតការងារនិងតម្លៃបន្ថែមជូនប្រជាពលរដ្ឋកាត់បន្ថយភាពក្រីក្រនិងចំណាកស្រុក និងជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

# សន្ទានុក្រម

**វាក្យសព្ទសំខាន់ៗដែលប្រើក្នុងគោលនយោបាយជាតិស្ដីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ ត្រូវកំណត់និយមន័យដូចខាងក្រោម៖**

**កសិកម្មតាមកិច្ចសន្យា**
(Contract farming)
សំដៅដល់ផលិតកម្មកសិកម្មផ្អែកលើកិច្ចសន្យារវាងអ្នកផលិត និងអ្នកទិញកសិផល ដែលបានព្រមព្រៀងគ្នាទៅលើបរិមាណផ្គត់ផ្គង់ គុណភាពកសិផល ថ្លៃកសិផល ពេលវេលាទិញលក់ ការផ្ដល់បច្ចេកទេសពូជ ជី ដើមទុន ជាដើម។

**កសិពាណិជ្ជកម្ម**
(Agro-Business)
សំដៅដល់ការដាំដុះផលិតផលសម្រាប់បម្រើឱ្យវិស័យពាណិជ្ជកម្ម នាំចេញ នាំចូល។

**កសិឧស្សាហកម្ម**
(Agro-industry)
សំដៅដល់សំណុំនៃសហគ្រាសឧស្សាហកម្មដែលផ្ដល់នូវឧបករណ៍និងសម្ភារៈកសិកម្ម( ជី ថ្នាំកសិកម្ម គ្រឿងចក្រ ) និងសហគ្រាសឧស្សាហកម្មដែលកែច្នៃ វេចខ្ចប់ និងបង្កើតលក្ខខណ្ឌឱ្យកសិផល( ឧស្សាហកម្មកសិចំណីអាហារ )។

**ការកសាងកេរ្តិ៍ឈ្មោះម៉ាកល្អ**
(Good Branding)
សំដៅដល់ការបង្កើតរូបភាពជាកម្មសិទ្ធិដែលអាចមើលឃើញ មានចំណាប់អារម្មណ៍ មានភាពសមហេតុសមផល និងមានចរិតជាវប្បធម៌ ដែលធ្វើឱ្យអតិថិជននឹកគិតដល់និងសម្គាល់ផលិតផលស្វាយចន្ទីកម្ពុជា។

**ខ្សែច្រវាក់តម្លៃ**
(Value Chain)
សំដៅដល់ដំណើរការឬស៊េរីនៃសកម្មភាពដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើតនិងបន្ថែមតម្លៃទៅលើការផលិតឬការកែច្នៃផលិតផលនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្មទាំងមូល។

**ខ្សែច្រវាក់ផ្គត់ផ្គង់**
(Supply Chains)
សំដៅដល់បណ្ដុំនៃសកម្មភាពរបស់អ្នកផ្គត់ផ្គង់សម្រាប់ការផលិត កែច្នៃ និងនាំចេញ។

**គ្រាប់ស្វាយចន្ទីមានសម្បក**
(Cashew Nut in Shell)
សំដៅដល់គ្រាប់ស្វាយចន្ទីដែលត្រូវបានប្រឡះចេញពីផ្លែស្វាយចន្ទី។

| | |
|---|---|
| **គ្រាប់ស្វាយចន្ទីគ្មានសម្បក**<br>(Cashew Nut Shelled) | សំដៅដល់គ្រាប់ស្វាយចន្ទីដែលត្រូវបានប្រឡេះចេញពីផ្លែរួចបកសម្បកក្រៅចេញ។ |
| **និរន្តរភាព**<br>(Continuity) | សំដៅដល់ភាពដែលអាចកើតមានជាបន្តបន្ទាប់ឥតដាច់ ឬលទ្ធភាពនៃការប្រើប្រាស់ជាបន្តបន្ទាប់ឥតដាច់នៃធនធានសេដ្ឋកិច្ចឬហិរញ្ញវត្ថុ ដោយពុំគិតបញ្ចូលការរក្សាបាន ឬការពង្រីកបាននូវគុណភាពនិងវឌ្ឍនភាព។ |
| **បរិយាបន្ន**<br>(Inclusiveness) | សំដៅដល់វិធានការឬគោលនយោបាយដែលរាប់បញ្ចូលឬផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីដំណើរការនៃការអនុវត្តគម្រោងកម្មវិធីឬគោលនយោបាយ។ |
| **ប្រព័ន្ធសុខដុមនីយកម្ម**<br>(Harmonized System (HS)) | សំដៅដល់ការធ្វើចំណាត់ថ្នាក់ទំនិញក្នុងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ដែលបានបង្កើតដោយអង្គការគយពិភពលោក។ |
| **ប្រព័ន្ធអេកូឡូស៊ី**<br>(Ecosystem) | សំដៅដល់បណ្តុំមុខងារនៃប្រព័ន្ធមួយ ដែលរួមផ្សំឡើងដោយភាវៈមានជីវិតនិងបរិស្ថានគ្មានជីវិតដែលនៅជុំវិញភាវៈមានជីវិតទាំងនោះ ព្រមទាំងមានអន្តរកម្មទៅវិញទៅមក( អន្តរកម្មរវាងភាវៈមានជីវិតនិងបរិស្ថានគ្មានជីវិត និងអន្តរកម្មរវាងភាវៈមានជីវិតទាំងនោះ )។ |
| **ពាណិជ្ជូបនីយកម្ម**<br>(Commercialization) | សំដៅដល់ការធ្វើពាណិជ្ជកម្មលើវិស័យកសិកម្ម ដែលមានជាអន្តរកម្មជាមួយវិស័យដទៃទៀត ដែលមានក្នុងសេដ្ឋកិច្ចហើយផលប៉ះពាល់របស់វាពឹងផ្អែកលើលក្ខខណ្ឌនៃវិស័យទាំងនេះ។ |
| **ពិពិធកម្ម**<br>(Diversification) | សំដៅដល់ការនៅចម្រុះផ្សេងគ្នានៃមូលដ្ឋានសេដ្ឋកិច្ច។ ពិពិធកម្មសេដ្ឋកិច្ច ជាសេដ្ឋកិច្ចចម្រុះផ្សេងគ្នានៃឧស្សាហកម្មវិស័យនានា កម្រិតជំនាញ និងកម្រិតការងារសម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានវិសាលភាពធំជាងមុន ប្រសើរជាងមុន។ |

**មជ្ឈមណ្ឌលឧត្តមភាព**
(Center of Excellence)

សំដៅដល់មជ្ឈមណ្ឌលដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតឡើងជាកន្លែងបណ្តុះបណ្តាល និងចែករំលែកចំណេះដឹងលើបច្ចេកទេសកសិកម្ម ដើម្បីកសាងសមត្ថភាពរបស់កសិករក្នុងការអភិវឌ្ឍវិស័យកសិកម្មតាមបច្ចេកវិទ្យាថ្មីៗ ឱ្យទទួលបាននូវប្រសិទ្ធភាពនិងប្រសិទ្ធផល។

**យន្តូបនីយកម្ម**
(Mechanization)

សំដៅដល់ដំណើរការរៀបចំឱ្យមានការប្រើប្រាស់គ្រឿងយន្តក្នុងដំណើរការផលិតកម្មនិងសេវាកម្ម ជំនួសការប្រើប្រាស់កម្លាំងមនុស្សឬសត្វ។

**សរីរាង្គតាមបែបប្រពៃណី**
(Organic by Default)

សំដៅដល់របៀបធ្វើកសិកម្មតាមធម្មជាតិ ប្រើប្រាស់ដីថ្មីដែលមិនធ្លាប់ប្រើប្រាស់ជីគីមី ប្រើប្រាស់តែជីកែច្នៃពីធម្មជាតិដោយអនុលោមតាមស្តង់ដាសរីរាង្គកំណត់ដោយទីផ្សារបញ្ជាទិញ។

**ស្វាយចន្ទី**
(Cashew)

សំដៅដល់ដំណាំស្វាយចន្ទី ដោយរាប់បញ្ចូលទាំងដើម ស្លឹក ផ្លែ និងគ្រាប់ស្វាយចន្ទី។

**ឧស្សាហូបនីយកម្ម**
(Industrialization)

សំដៅដល់ការប្រែក្លាយការផលិតបែបគ្រួសារឱ្យទៅជាការផលិតបែបឧស្សាហកម្ម។

## ឧបសម្ព័ន្ធទី១ : ម៉ាទ្រីសនៃផែនការគោលនយោបាយជាតិស្ដីពីស្វាយចន្ទី និងផែនការសកម្មភាព

